"ខ្ញុំមានចិត្តសប្បាយរីករាយយ៉ាងខ្លាំងដែលបានចូលរួមក្នុងសហគ្រាសទឹកឃ្មុំ ពីព្រោះវាបានផ្តល់ឱ្យខ្ញុំ និងអ្នកភូមិដទៃទៀតនៅក្នុងឃុំក្រង់តេសទទួលបាននូវអត្ថប្រយោជន៍ជាច្រើនដែលជាកត្តាមួយរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ និងថែរក្សាប្រពៃណីដែលដូនតាយើងបានបន្សល់ទុកឱ្យ ។"

លោក សៀន ថា
ប្រធានក្រុមប្រមូលទឹកឃ្មុំ

ចេញពីព្រៃ | ការស្ទង់សំណើម | ការថ្លឹង | ការច្រោះលើកទី២ | អ្នកទិញទឹកឃ្មុំស្រស់ | ការច្រក និងការវេចខ្ចប់






ផលិតផលសម្រេច | ផលិតផលទឹកឃ្មុំព្រៃមណ្ឌលគិរីមានលក់នៅតាមទីផ្សារក្នុងខេត្តមណ្ឌលគិរី និងតាមហាង ព្រមទាំងផ្សារទំនើបនៅរាជធានីភ្នំពេញ

## ការអភិរក្សជីវចម្រុះ និងការជួយលើកស្ទួយជីវភាពប្រជាជនមូលដ្ឋាន នៅក្នុងតំបន់ព្រៃទេសភាពភាគខាងកើតនៃប្រទេសកម្ពុជា

◗ WWF ធ្វើការជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការអភិរក្សបណ្តុំព្រៃល្បោះ និងសត្វព្រៃដែលមានតម្លៃជាសាកលជាច្រើនប្រភេទនៅក្នុងប្រទេសកម្ពុជា ។ គម្រោងនេះផ្តោតលើការងារគ្រប់គ្រង និងការពារតំបន់អភិរក្សចំនួនពីរគឺ ព្រៃការពារមណ្ឌលគិរី និងដែនជម្រកសត្វព្រៃភ្នំព្រេចដែលតំបន់ទាំងពីរនេះរួមបញ្ចូលគ្នាមានផ្ទៃក្រលាសរុបប្រមាណ ៦ 000 គីឡូម៉ែត្រការ៉េ ។ គម្រោងមានទិសដៅថែរក្សា និងការពារបណ្តុំព្រៃទេសភាពកម្ពុជាដែលនៅសេសសល់ចុងក្រោយនេះឱ្យនៅស្រស់ស្អាត ហើយតភ្ជាប់គ្នា និងជួយប្រជាជនក្នុងការការពារធនធានសត្វព្រៃ ព្រមទាំងលើកកម្ពស់ការចិញ្ចឹមជីវិតរបស់ពួកគេប្រកបដោយនិរន្តរភាព ។ សកម្មភាពសំខាន់ៗដែលអង្គការ WWF កំពុងអនុវត្តនៅក្នុងតំបន់ព្រៃទេសភាពភាគខាងកើត រាប់បញ្ចូលការគ្រប់គ្រងតំបន់ការពារ ការអភិរក្សសត្វព្រៃ និងទីជម្រកធម្មជាតិ ការលើកស្ទួយវិស័យទេសចរធម្មជាតិដោយមានការចូលរួមពីសហគមន៍ ការអប់រំផ្សព្វផ្សាយ និងលើកកម្ពស់ការចិញ្ចឹមជីវិត ។

◗ NTFP-Exchange Programme ប្រចាំភាគខាងត្បូង និងអាស៊ីអាគ្នេយ៍ គឺជាបណ្តាញសហប្រតិបត្តិការនៃអង្គការមិនមែនរដ្ឋាភិបាល និងក្រុមសហគមន៍មូលដ្ឋានដែលធ្វើការជាមួយបណ្តាសហគមន៍ព្រៃឈើដើម្បីពង្រឹងសមត្ថភាពសហគមន៍ក្នុងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព ។ សកម្មភាពរបស់ NTFP-EP រួមមានការបង្កើតបណ្តាញ ការចែករំលែកបទពិសោធន៍ និងផ្សព្វផ្សាយចំណេះដឹងលើវិស័យគោលនយោបាយ ការគាំទ្រផ្នែកបច្ចេកទេស និងអភិវឌ្ឍសហគ្រាស និងការស្វែងរកទីផ្សារ ។

### Mondulkiri wild honey outlets

| | | |
|---|---|---|
| **សែនមនោរម្យ** | ◗មជ្ឈមណ្ឌលជនជាតិព្នង | ◗ហាងក្រុមទឹកឃ្មុំ |
| **ភ្នំពេញ** | ◗ផ្សារទំនើបឡាក់គី, #160,មហាវិថីព្រះសីហនុ<br>◗NTFP-EP, #10Eo, ផ្លូវ 420<br>◗CEDAC shops, #689, មហាវិថីកម្ពុជាក្រោម<br>#13, ផ្លូវ 360, #67, ផ្លូវ 230 | ◗ផ្សារផេនសល , #15, ផ្លូវ 214<br>◗ផ្សារផាវ៉ាហ្គន , #45, ផ្លូវ 220 |

World Wide Fund for Nature (WWF)
WWF Greater Mekong-Cambodia Country Programme
#54, Street 352, Sangkat Boeung Keng Kang I,
Khan Chamkarmorn, Phnom Penh, Cambodia
P.O.Box 2467
Tel: +855 23 218 034, Fax: +855 23 211 909
E-mail: wwfcambodia@wwfgreatermekong.org
www.cambodia.panda.org

Non-Timber Forest Products Exchange Programme for South and Southeast Asia (NTFP-EP)
Cambodia Programme Office
#10Eo, Street 420, Sangkat Boeung Trabek
Khan Chamkarmon, Phnom Penh, Cambodia
E-mail: ntfp_epc@online.com.kh, ntfp-marketing@online.com.kh
Tel: +855 23 727 407
http://www.ntfp.org
http://groups.yahoo.com/group/ntfpcambodia

Project partners: Sahakreas CEDAC, NTFP Working Group.
Supported by: Habitat, DfID/Danida, ADB-BCI, EGP, ITTTO and FAO.

Text, design and photos 2009 ©. Amalia Maling, Femy Pinto, Laura Martelli.
Khmer text editing 2010 © Tep Asnarith, Eng Mengey



# ចេញពីព្រៃ ទៅ ទីផ្សារ

## សហគ្រាសទឹកឃ្មុំព្រៃខេត្តមណ្ឌលគិរី

សហគ្រាសសហគមន៍ គឺជាសហគ្រាសមួយដែលជម្រុញឱ្យមានការចូលរួមក្នុងការអភិរក្សព្រៃឈើ ក៏ដូចជាលើកកម្ពស់ជីវភាពរស់នៅរបស់ជនជាតិដើមភាគតិចដែលពឹងផ្អែកលើធនធានព្រៃឈើ ។
សហគ្រាសទឹកឃ្មុំព្រៃអនុវត្តគោលការណ៍សំខាន់ៗចំនួន ៤ រួមមានៈ

- ការអភិរក្សព្រៃឈើ
- ការប្រើបច្ចេកទេសយកទឹកឃ្មុំលក្ខណៈប្រពៃណីប្រសើរជាងមុនដើម្បីប្រមូលទឹកឃ្មុំប្រកបដោយនិរន្តរភាព
- សមធម៌នៅក្នុងជីវភាពរស់នៅរបស់សហគមន៍
- ការលើកកម្ពស់សិទ្ធិស្វ័យសម្រេច និងគ្រប់គ្រងរបស់សហគមន៍

## ការនាំមកនូវឱកាសរកប្រាក់ចំណូលបន្ថែមប្រកបដោយនិរន្តរភាព សម្រាប់សហគមន៍មូលដ្ឋានតាមរយៈការអភិរក្សជីវចម្រុះ

សហគ្រាសទឹកឃ្មុំមានគោលបំណងធ្វើឱ្យជីវភាពរស់នៅរបស់ប្រជាជនដែលពឹងផ្អែកលើធនធានព្រៃឈើកាន់តែប្រសើរឡើង តាមរយៈការជួយបណ្តុះបណ្តាលបច្ចេកទេសប្រមូលទឹកឃ្មុំប្រកបដោយនិរន្តរភាព និងការស្វែងរកទីផ្សារទឹកឃ្មុំ ។

សហគ្រាសទឹកឃ្មុំបានដំណើរការចាប់តាំងពីឆ្នាំ ២00៧មក ហើយបានរួមចំនែកក្នុងការលើកកម្ពស់ការចិញ្ចឹមជីវិតរបស់អ្នកប្រមូលទឹកឃ្មុំជនជាតិដើមភាគតិចព្នងក្នុងឃុំសាកល្បងចំនួនពីរនៅក្នុងខេត្តមណ្ឌលគិរី ។

គម្រោងនេះផ្តល់ប្រយោជន៍លើផ្នែកសេដ្ឋកិច្ច វប្បធម៌ និងបរិស្ថាន ។

## • • • • • • • • • • • • • សហគមន៍ជនជាតិដើមភាគតិចព្នង

ព្រៃមណ្ឌលគិរី ជួយទ្រទ្រង់ការចិញ្ចឹមជីវិតរបស់ជនជាតិដើមភាគតិចព្នងដែលចាត់ទុកព្រៃឈើជាលំនៅដ្ឋាន ទីផ្សារ ឃ្លាំងឱសថ និងជាផ្នែកដ៏សំខាន់មួយនៃវប្បធម៌របស់ពួកគាត់ ។



- ◗ ៥២ភាគរយនៃចំនួនប្រជាជននៅក្នុងខេត្តមណ្ឌលគិរី គឺជាជនជាតិដើមភាគតិចព្នង
- ◗ ពួកគាត់គឺជាកសិកររស់នៅក្នុងភូមិតូចៗស្ថិតនៅក្នុង និងជុំវិញតំបន់ព្រៃការពារ
- ◗ ពួកគាត់អនុវត្តកសិកម្មពនេចរ
- ◗ ពួកគាត់ពឹងផ្អែកយ៉ាងខ្លាំងទៅលើធនធានព្រៃឈើសម្រាប់ជាអាហារ ឱសថ ប្រាក់ចំណូល ជំនឿអារក្ស
- ◗ វប្បធម៌ប្រពៃណី និងការគ្រប់គ្រងធនធានធម្មជាតិរបស់ពួកគាត់បង្កផលប៉ះពាល់តិចតួចណាស់ទៅលើព្រៃឈើ
- ◗ ប្រពៃណីជនជាតិដើមដ៏សម្បូរបែប កំពុងទទួលរងគំរាមកំហែងដោយការទាញផលពីធម្មជាតិបែបពាណិជ្ជកម្មឆាប់រហ័ស

## ជីវចម្រុះរបស់ខេត្តមណ្ឌលគិរី• • • • • • • • • • • • • •




ខេត្តមណ្ឌលគិរី ដែលស្ថិតនៅទិសឥសាន្តនៃប្រទេសកម្ពុជា គ្រប់ដណ្តប់លើផ្ទៃដី ១.៥លានហិកតា ។ ផ្ទៃដីភាគច្រើនគ្របដណ្តប់ដោយព្រៃមិនទាន់មានការរុករាន និងព្រៃដំណុះឡើងវិញចំនួន ៩១% ក្នុងនោះមានព្រៃល្បោះ ៤៨.៥% ព្រៃពាក់កណ្តាលស្រោង ២0% និងព្រៃស្រោង ១0.៥% ។ ព្រៃឈើទាំងអស់នេះបានផ្តល់នូវទីជម្រកដ៏ល្អមួយសម្រាប់ឃ្មុំព្រៃ (Apis Dosata and Apis Florea) និងជាជម្រកសម្រាប់ពពួកថនិកសត្វមួយចំនួនដូចជាៈ ខ្លាធំ ដំរីអាស៊ី ខ្ទីង ទន្សោង និងពពួកសត្វបក្សីដទៃទៀត ។ វាក៏ជាតំបន់មានសក្តានុពលបំផុតសម្រាប់ការស្តារចំនួនសត្វខ្លាធំឡើងវិញផងដែរ ។

សីហា ២០១០

# ការកំណត់បញ្ហាប្រឈម

ការចិញ្ចឹមជីវិតរបស់សហគមន៍ ដែលពឹងផ្អែកទៅលើព្រៃឈើនៅប្រទេសកម្ពុជាងាយនឹងទទួលរងនូវគ្រោះថ្នាក់ ដោយសារការធ្លាក់ចុះ និងកត្តាគំរាមកំហែងទៅលើដីព្រៃ និងធនធានធម្មជាតិនៅក្នុងប្រទេស។ សហគមន៍ជនជាតិដើមភាគតិចពួងជាច្រើន ពឹងអាស្រ័យលើការប្រមូលអនុផលព្រៃឈើសម្រាប់ការប្រកបរបរចិញ្ចឹមជីវិត។ ៤0% នៃប្រាក់ចំណូលរបស់ពួកគាត់ ទទួលបានមកពីការប្រមូលទឹកឃ្មុំព្រៃ និងអនុផលព្រៃឈើផ្សេងៗទៀត។

ពួកគាត់ប្រឈមមុខនឹងឧបសគ្គខាងក្រៅ និងការរៀបចំមួយចំនួនដូចជា:

## ទីផ្សារ

- ខ្វះការគាំទ្រសម្រាប់សមាជិកសហគមន៍ជនជាតិដើមភាគតិចពួង
- ឈ្មួញឱ្យតម្លៃទឹកឃ្មុំទាប (២.៥ ដុល្លាក្នុង១លីត្រ)
- ដោយសារតែមានការប្រកួតប្រជែង អ្នកផលិតទឹកឃ្មុំបានបង្កើនបរិមាណទឹកឃ្មុំតាមរយៈការលាយទឹកឃ្មុំជាមួយទឹក និងស្ករ

## បច្ចេកទេសនៃការប្រមូលទឹកឃ្មុំ

- ការប្រមូលគ្មាននិរន្តរភាព: កាត់យកផ្លិតឃ្មុំទាំងមូលចេញ និងសម្លាប់សត្វឃ្មុំទាំងអស់នៅក្នុងសំបុក។
- ការប្រើបច្ចេកទេសមិនសមស្រប និងគ្មានអនាម័យ: ច្របាច់ទឹកឃ្មុំដោយដៃ កង្វះខាតបច្ចេកទេសក្នុងការច្រោះ និងសម្ភារៈប្រើប្រាស់ ប្រើធុងមិនសំអាតសម្រាប់ដាក់ទឹកឃ្មុំ ហើយប្រើដបច្រកម្តងហើយសម្រាប់ច្រកទឹកឃ្មុំម្តងទៀត ដោយមិនបានលាងសំអាត។

ជនជាតិដើមភាគតិចពួងត្រូវការជាចាំបាច់នូវធនធានព្រៃឈើសម្រាប់ការចិញ្ចឹមជីវិត។ ពួកគេជឿថា សុខភាព សុភមង្គលរបស់ក្រុមគ្រួសារ ក៏ដូចជាសហគមន៍ទាំងមូលពឹងអាស្រ័យលើការថែរក្សាទំនាក់ទំនងដ៏ជិតស្និទ្ធជាមួយបុព្វបុរស និងអារក្សអ្នកតានៅក្នុងធម្មជាតិ។



ពួកគាត់គិតថាពួកគាត់ត្រូវតែប្រើប្រាស់ព្រៃឈើឱ្យដូចសត្វឃ្មុំដែរពោលគឺ "យើងទាញផលប្រយោជន៍ពីព្រៃឈើ ដូច្នេះយើងត្រូវតែការពារព្រៃឈើវិញ។"

# ដំណោះស្រាយដែលរកឃើញដោយសហគមន៍

បន្ទាប់ពីការពិភាក្សា និងចូលរួមក្នុងសិក្ខាសាលា ហើយនឹងការធ្វើទស្សនៈកិច្ចសិក្សា សមាជិកសហគមន៍បានសម្រេចចិត្តអនុវត្តគម្រោងសហគ្រាសទឹកឃ្មុំ។

គម្រោងសាកល្បងនេះលើកស្ទួយការអភិវឌ្ឍន៍ការចិញ្ចឹមជីវិតដោយមានការចូលរួមពីសហគមន៍ ហើយមានតម្លៃទាំងផ្នែកសង្គម វប្បធម៌ និងការងារអភិរក្សព្រៃឈើ។

អង្គការ WWF, NTFP-EP និងស្ថាប័នពាក់ពាក់ដទៃទៀតបានជួយសម្របសម្រួលសកម្មភាពអភិវឌ្ឍរចនាសម្ព័ន្ធជាមួយអ្នកប្រមូលទឹកឃ្មុំជនជាតិដើមភាគតិចពួង។

ឥឡូវនេះពួកគាត់បានចងក្រងគ្នាជាក្រុមសហគ្រាសទឹកឃ្មុំថ្នាក់ឃុំ ហើយទទួលបានការបណ្តុះបណ្តាលសមត្ថភាព និងការគាំទ្រផ្នែកបច្ចេកទេសពាក់ព័ន្ធនឹងការងារគ្រប់គ្រងធនធាន និងហិរញ្ញវត្ថុ បច្ចេកទេសនៃការប្រមូលទឹកឃ្មុំប្រកបដោយនិរន្តរភាព ការគ្រប់គ្រងគុណភាពទឹកឃ្មុំ និងការស្វែងរកទីផ្សារ។

តាមរយៈគម្រោងសាកល្បងនេះ អង្គការ WWF និង NTFP-EP កំពុងលើកស្ទួយការការពារ និងការទទួលស្គាល់ប្រពៃណីជនជាតិដើមភាគតិចពួង និងការគ្រប់គ្រងធនធានធម្មជាតិ ស្របតាមរបបគ្រប់គ្រងសហគមន៍ព្រៃឈើសហគមន៍នៃប្រទេសកម្ពុជា ។

គម្រោងនេះប្រតិបត្តិតាមគោលការណ៍អភិរក្ស និងអភិវឌ្ឍដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន។

Honey collection areas




ជ្រើសរើសដើមឈើដែលមានឃ្មុំ — រៀបចំគប់ផ្សែង — ឡើងបង្ហុយផ្សែងយកឃ្មុំ — កាំបិតដែលធ្វើពីឈើ និងស្រោមដៃត្រូវបានប្រើ



ដាក់លេខសម្គាល់ដើមឈើដើម្បីធ្វើផែនទីតំបន់ឃ្មុំ — សំបុកឃ្មុំ — ទឹកឃ្មុំនៅក្នុងតំរង់នៅកន្លែងយក

# សកម្មភាព និងលទ្ធផល

| | |
|---|---|
| ពង្រឹងសមត្ថភាព និងសហគ្រាសទឹកឃ្មុំ ដោយមានការចូលរួមពីសហគមន៍ | ▸ ការបង្កើត និងកសាងសមត្ថភាពក្រុមប្រមូលទឹកឃ្មុំដោយគ្រប់គ្រងប្រព័ន្ធពាណិជ្ជកម្មទឹកឃ្មុំពីថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់ខេត្ត ហើយនឹងការគ្រប់គ្រងគុណភាពទឹកឃ្មុំ។ |
| ពង្រឹងគុណភាព និង ផលិតកម្មទឹកឃ្មុំ | ▸ ធ្វើការផ្សព្វផ្សាយ និងប្រើប្រាស់ចំណេះដឹង និងជំនាញរបស់បងប្អូនជនជាតិភាគតិចសម្រាប់ការប្រមូលទឹកឃ្មុំ<br>▸ លើកកម្ពស់ការប្រមូលទឹកឃ្មុំ បច្ចេកទេសកែច្នៃ និងការវេចខ្ចប់ដើម្បីធានានូវនិរន្តរភាពសម្រាប់ការប្រមូល និងគុណភាពផលិតផល។ |
| បែងចែកប្រាក់ចំណូល និងអត្ថប្រយោជន៍ផ្សេងៗទៀត | ▸ ការពិភាក្សាថ្នាក់សហគមន៍ និងកិច្ចព្រមព្រៀង ដើម្បីឈានទៅសម្រេចបាននូវតម្លៃសមរម្យសម្រាប់ទឹកឃ្មុំ<br>▸ ធ្វើការកំណត់ការបែងចែកផលប្រយោជន៍ដូចជា: ឧបករណ៍ និងសម្ភារៈជំនួយ ការបណ្តុះបណ្តាល និងផ្សព្វផ្សាយការគ្រប់គ្រងធនធាន ការធ្វើសហប្រតិបត្តិការ និងដំណើរការដើមទុន។ |
| បង្កើនការយល់ដឹង និងចែករំលែកចំណេះដឹង | ▸ ចងក្រងជាឯកសារ និងចែកចាយចំណេះដឹង និងការអនុវត្តន៍ល្អៗរបស់បងប្អូនជនជាតិភាគតិចលើការប្រមូលទឹកឃ្មុំការការពារព្រៃឈើ និងសំបុកឃ្មុំ។<br>▸ សិក្សាពីបទពិសោធន៍ និងការអនុវត្តន៍ល្អៗរបស់អ្នកពាក់ព័ន្ធផ្សេងទៀត |
| គាំទ្រការស្វែងរកទីផ្សារ និងការធ្វើអាជីវកម្ម | ▸ ជួយធ្វើការវេចខ្ចប់ និងពាក់ស្លាកយីហោ លើកកម្ពស់ការលក់ដូរ និងការងារដទៃផ្សេងទៀត<br>▸ សម្របសម្រួលក្នុងការធ្វើកិច្ចព្រមព្រៀងលក់ដូរតាមរយៈបណ្តាញជាច្រើន<br>▸ ទំនាក់ទំនងជាមួយផ្នែកឧស្សាហកម្ម រដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយពតិមាននានា |
| ការគ្រប់គ្រង និងការការពារព្រៃឈើ | ▸ អភិវឌ្ឍតារាងទិន្នន័យសម្រាប់តាមដានការប្រមូលទឹកឃ្មុំ<br>▸ ធ្វើការគូសផែនទីកំណត់ធនធាន និងសកម្មភាពបិទផ្លាកតាមដើមឈើជាដើម<br>▸ សហការណ៍ជាមួយអាជ្ញាធរមូលដ្ឋាន និងរដ្ឋាភិបាលលើការងារត្រួតពិនិត្យ និងដើរល្បាតព្រៃការពារ |



ការបង្កើតស្លាកយីហោ (ម៉ាក) របស់សហគមន៍ "ទឹកឃ្មុំព្រៃខេត្តមណ្ឌលគីរី"

ផ្តល់អត្ថប្រយោជន៍ទៅដល់ ១៦៩ គ្រួសារ ក្នុងភូមិចំនួន ៨

តម្លៃទឹកឃ្មុំកើនឡើងទ្វេរដងនៅលើទីផ្សារក្នុងស្រុក

ប្រាក់ចំណូលសហគមន៍កើនឡើងដល់ ២០%

ផលិតផលមានតម្លៃសមរម្យ
អ្នកប្រមូលទឹកឃ្មុំទទួលបាន ៧៣% នៃតម្លៃលក់

ដំណើរការផលិតស្របតាមគុណភាពស្តង់ដារ

ទឹកឃ្មុំត្រូវបានប្រមូលប្រកបដោយនិរន្តរភាព

ប្រជាសហគមន៍ចេះផ្តួចផ្តើមសកម្មភាពល្អៗ
ដើម្បីការពារព្រៃឈើ

ការលើកតម្កើងតម្លៃជំនឿលើអារក្សអ្នកតា និងសាមគ្គីភាព

## សម្រាប់រយៈពេល ៣ ឆ្នាំខាងមុខ

- ភូមិជាច្រើនដទៃទៀតនឹងចូលរួម
- គ្រួសារជាច្រើនដទៃទៀតនឹងទទួលបានប្រយោជន៍
- ក្នុងប្រាក់ចំណូលសរុបរបស់សហគមន៍ ទឹកឃ្មុំអាចរួមចំណែករហូតដល់ ៧0%
- ផលិតកម្ម និងគុណភាពទឹកឃ្មុំមានលក្ខណៈស្តង់ដារអន្តរជាតិ